មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
National Maternal and Child Health Center

# ទិវាសល្យសាស្ត្រ សម្ភព និងរោគស្ត្រី លើកទី៣

ប្រធានបទ៖ «**ពង្រឹង និងបង្កើនសេវាព្យាបាល ថែទាំ សង្គ្រោះ ប្រកបដោយគុណភាព**»

## ការលើកកម្ពស់ការចិញ្ចឹមកូនដោយទឹកដោះម្តាយសុទ្ធ





ថ្ងៃទី៤-៥ ខែកញ្ញា ឆ្នាំ២០២៥
សណ្ឋាគារភ្នំពេញ

រៀបរៀង និងធ្វើបទបង្ហាញដោយ៖ លោកស្រី អួង លីដា ប្រធានគណៈកម្មការថែទាំ
នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

# មាតិកា

១. អត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយ
២. សកម្មភាពការលើកកម្ពស់ការចិញ្ចឹមកូនដោយទឹកដោះ
ម្ដាយនៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
៣. ភាពខ្លាំងនៃសកម្មភាពគាំទ្រ
៤. បញ្ហាប្រឈមនិងផលពិបាករបស់ក្រុមគាំទ្រ

# ១. តើទឹកដោះម្ដាយពិតជាមានអត្ថប្រយោជន៍ ចំពោះទារក (កូនមនុស្ស) មែនដែរឬទេ

?

# On World Breastfeeding Week

សេចក្តីថ្លែងការណ៍របស់ Catherine Russell និង Tedros Adhanom (នាយក WHO / UNICEF) បានថ្លែងថា៖

" ក្នុងរយៈពេល ១២ឆ្នាំចុងក្រោយនេះ ចំនួនទារកក្រោមអាយុ ៦ខែដែលបំបៅដោយទឹកដោះម្តាយសុទ្ធបានកើនឡើងច្រើនជាង ១០% មានន័យថា ៤៨% នៃទារកនៅទូទាំងពិភពលោកសព្វថ្ងៃនេះទទួលបានអត្ថប្រយោជន៍ពីការចាប់ផ្តើមជីវិតដែលមានសុខភាពល្អនេះ និងបង្ហាញថា៖

ទារករាប់រយរាប់ពាន់នាក់ដែលជីវិតរបស់ពួកគេត្រូវបានសង្គ្រោះដោយការបំបៅកូនដោយទឹកដោះម្តាយ "

31 July 202 Geneva / New York

**បន្ត....**

WHO បានណែនាំឱ្យបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រយៈពេល ៦ខែដំបូងនៃជីវិតរបស់ទារក ព្រោះថា៖
" ទឹកដោះម្តាយផ្តល់សារធាតុចិញ្ចឹមចាំបាច់គ្រប់មុខទាំងអស់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍន៍ដ៏ល្អប្រសើរ"

" ទឹកដោះម្តាយក៏ងាយរំលាយ និងមានអង្គបដិប្រាណដែលការពារប្រឆាំងនឹងជំងឺទូទៅជាច្រើនរបស់ទារក"

WHO, 2024

# តើអត្ថប្រយោជន៍អាហាររូបត្ថម្ភនៃការបំបៅ
# កូនដោយទឹកដោះម្ដាយចំពោះទារកមានអ្វីខ្លះ

# ?


អាហាររូបត្ថម្ភ
តាមបំណង
សមតុល្យ
សមស្រប
ការការពារ
ដោយភាពស៊ាំ
សម្រួលដល់ការ
រំលាយអាហារ
ជំនួយក្នុងការ
លូតលាស់ និង
ជួសជុល
អរម៉ូន
កត្តាលូត
លាស់
ជំនួយដល់ការ
អភិវឌ្ឍន៍
ខួរក្បាល
សារធាតុរ៉ែ
សំខាន់ៗ
សម្បូរ
វីតាមីន

# តើលោកគ្រូអ្នកគ្រូដឹងពីការពិតនៃការចិញ្ចឹមកូនឬទេ?

១. ជីវិតកុមារជាង ៨២០ ០០០នាក់ ត្រូវបានរក្សា (រស់) ជារៀងរាល់ឆ្នាំក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ បើកុមារទាំងអស់ដែលមានអាយុពី ០-២៣ខែ បានបំបៅដោយទឹកដោះម្ដាយដែលល្អបំផុត។

២. ការបំបៅកូនដោយទឹកដោះម្ដាយធ្វើអោយប្រសើរឡើងនូវ IQ ការចូលសាលា និងត្រូវបានផ្សារភ្ជាប់ជាមួយនឹងប្រាក់ចំណូលខ្ពស់នៅក្នុងជីវិតមនុស្សពេញវ័យ។

WHO, 20 December 2023

**បន្ត...**

៣. កង្វះអាហារូបត្ថម្ភត្រូវបានផ្សារភ្ជាប់ជាមួយនឹង ៤៥% នៃការស្លាប់របស់កុមារ

៤. ទូទាំងពិភពលោកក្នុងឆ្នាំ ២០២២ មាន៖

- កុមារ ១៤៩លាននាក់ដែលមានអាយុក្រោម ៥ឆ្នាំត្រូវបានគេប៉ាន់ប្រមាណថាមានភាពក្រិះក្រិន (ខ្លីពេកសម្រាប់អាយុ)
- កុមារ ៤៥លាននាក់ត្រូវបានគេប៉ាន់ស្មានថាភាពក្រិះក្រិន (ទាបពេកសម្រាប់កម្ពស់)
- កុមារ ៣៧លាននាក់ លើសទម្ងន់ឬធាត់ពេក

WHO, 20 December 2023

# ការចិញ្ចឹមទារកក្នុងស្ថានភាពលំបាកជាពិសេស

ការបំបៅកូនដោយទឹកដោះម្តាយនៅតែជារបៀបនៃការផ្តល់អាហារដល់ទារកក្នុងស្ថានភាពលំបាកស្ទើរតែទាំងអស់ ។
ឧទា៖

១.ទារកទើបនឹងកើតទម្ងន់ទាបឬមិនគ្រប់ខែ
២. ម្តាយដែលរស់នៅជាមួយមេរោគអេដស៍
៣. ម្តាយវ័យជំទង់ (ក្មេង)
៤. ទារកនិងកុមារតូចដែលខ្វះអាហារូបត្ថម្ភ
៥. គ្រួសារដែលទទួលរងនូវផលវិបាក

WHO, 20 December 2023

# ២. សកម្មភាពការលើកកម្ពស់ការចិញ្ចឹមកូនដោយទឹកដោះម្ដាយនៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

១. ការអប់រំសុខភាពអំឡុងពេលស្នាក់នៅក្នុងមន្ទីរពេទ្យ

២. ការអប់រំសុខភាពមុនពេលចេញទៅផ្ទះ









# សកម្មភាពជួយស្ត្រីដាក់ទារកឲ្យស្បែកប៉ះស្បែក ដើម្បីទារកឆាប់បានបៅដោះម្តាយក្រោយសម្រាល







# សកម្មភាពជួយស្ត្រីដាក់ទារកឲ្យស្បែកប៉ះស្បែក នៅក្នុងបន្ទប់វះកាត់





# សកម្មភាពថែទាំទារកដោយទឹកដោះម្ដាយ
# នៅក្នុងបន្ទប់ថែទាំទារក









ទារកដែលបានដាក់ស្បែកប៉ះស្បែកនៅ OT
35%
30%
25%
20%
15%
10%
5%
0%
9%
29%
28%
25%
ត្រីមាសទី១(២០២៤-២០២៥)
ត្រីមាសទី២(២០២៤-២០២៥)
2024
2025


ទារកដែលបានបៅទឹកដោះម្ដាយម៉ោងដំបូង
98%
96%
94%
92%
90%
88%
86%
84%
82%
80%
78%
96%
84%
90%
94%
2024
2025
ត្រីមាសទី១(២០២៤-២០២៥)
ត្រីមាសទី២(២០២៤-២០២៥)

## ការប្រៀបធៀបអំពីការគាំទ្រការបំបៅកូនដោយទឹកដោះម្តាយសុទ្ធ ( គិតជា% )



# ការបំបៅកូនដោយទឹកដោះម្តាយសម្រាប់ទារកដែលកើតពីម្តាយមានមេរោគ អេដស៍ រលាកថ្លើមប្រភេទបេ និងស្វាយ

- ភ្លាមៗក្រោយពេលសម្រាលម្តាយត្រូវតែទទួលបានការប្រឹក្សាយ៉ាងយកចិត្តទុកដាក់អំពីឆ្មបពីជម្រើសនៃការចិញ្ចឹមទារកដើម្បីចាប់ផ្តើមអនុវត្តវិធីចិញ្ចឹមខណៈពេលដែលស្ត្រីកំពុងស្ថិតនៅក្នុងមន្ទីរពេទ្យនៅឡើយ
- ទោះបីមានហានិភ័យខ្ពស់នៃការចម្លងពីម្តាយទៅកូននៃមេរោគអេដស៍ក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយក៏ដោយ ប៉ុន្តែគ្រោះថ្នាក់នៃការចិញ្ចឹមដោយទឹកដោះគោដែលមិនត្រឹមត្រូវ ឬការបំបៅលាយគ្នាគឺមានទំហំធំជាង

គោលការណែនាំជាតិសម្រាប់ការបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្តាយទៅកូន ទំព័រ៧៣

## បន្ត....

- ចំពោះម្តាយវិជ្ជមានរលាកថ្លើមប្រភេទបេ មិនមានភស្តុតាងបង្ហាញថា៖

ការបំបៅកូនដោយទឹកដោះម្តាយបង្កើនហានិភ័យនៃការចម្លង ពីម្តាយទៅកូននូវមេរោគរលាកថ្លើមប្រភេទបេនោះទេ

ដូច្នេះ

ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ត្រូវបាន គាំទ្រលើកទឹកចិត្ត

គោលការណែនាំជាតិសម្រាប់ការបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្តាយទៅកូន ទំព័រ៧៣

## បន្ត...

- ចំពោះម្ដាយវិជ្ជមានមេរោគស្វាយ មិនមានភស្តុតាងណាមួយដែលបញ្ជាក់ពីការឆ្លងមេរោគស្វាយតាមរយៈទឹកដោះម្ដាយទេ ដូច្នេះ

សូម្បីតែម្ដាយដែលទើបតែចាប់ផ្ដើមការព្យាបាលជម្ងឺស្វាយ ក៏គួរត្រូវបានលើកទឹកចិត្តឱ្យបំបៅកូនដោយទឹកដោះម្ដាយរបស់គាត់ដែរ

គោលការណែនាំជាតិសម្រាប់ការបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្ដាយទៅកូន ទំព័រ៧៣

# បញ្ហាប្រឈម

១. កត្តាស្ត្រី (សុខភាពនិងការងារ)
២. កត្តាគ្រួសារ (ខ្វះការគាំទ្រពីគ្រួសារ)
៣. កត្តាសង្គម (បរិយាកាសជុំវិញដូចជា៖ ការផ្សព្វផ្សាយពាណិជ្ជកម្ម មិត្តភក្តិ.....)
៤. កត្តាអ្នកផ្តល់សេវា (ចំនួនសម្រាលច្រើន អ្នកផ្តល់សេវាខ្លះមិនសូវចូលរួម)

# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់



មជ្ឈមណ្ឌលគំរូចិញ្ចឹមកូនដោយទឹកដោះម្តាយ

Center of Excellence for Breastfeeding